# ព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ .- បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុករៀបចំ និងអភិវឌ្ឍន៍គោលនយោបាយ សំរាប់រយៈពេលខ្លី មធ្យម និងវែង ដើម្បីជំរុញអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាហៅថា អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យ បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ( National Intormation Communications Technology Development Authority ) ដែលមានសមាសភាពដូចតទៅនេះ :

១-សម្តេច ហ៊ុន សែន ជាប្រធាន

២-ឯកឧត្តម សុខ អាន ជាអនុប្រធាន

៣-ឯកឧត្តម ជាន់ តិន ជាសមាជិក

៤-ឯកឧត្តម ប៉ាន់ សូរស័ក្តិ ជាសមាជិក

៥-ឯកឧត្តម ភូ លីវុឌ្ឍ ជាសមាជិក និងជាអគ្គលេខាធិការមានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ .- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាមានភារកិច្ច :

-រៀបចំគោលនយោបាយ សំរាប់រយៈពេលខ្លី មធ្យម និងវែងដើម្បីជំរុញការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។

Downloaded from http://www.khmerlaws.com

-អនុវត្តគោលនយោបាយជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដើម្បីជំរុញការអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចជា អតិបរមា ។

-ពិនិត្យតាមដាន និងធ្វើសវនកម្មលើរាល់កិច្ចការដែលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។

មាត្រា ៣ .- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

មាត្រា ៤ .- អគ្គលេខាធិការរង សមាជិក និងក្រុមការងារជំនាញដទៃទៀត នឹងកំណត់តែងតាំងតាមគោលការណ៍ច្បាប់ជាធរមាន តាមសំណើរបស់ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។

មាត្រា ៥ .- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់សំរបសំរួលការងារ ។ សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៦ .- ការចំណាយទាំងអស់សំរាប់បំរើអោយសកម្មភាពអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាវិទ្យា ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងថវិកាដែលទទួលបានពីការឧបត្ថម្ភទ្វេភាគី ឬពហុភាគី ។

មាត្រា ៧ .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៩ .- ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

Downloaded from http://www.khmerlaws.com